# បណ្ណសន្យារ៉ាប់រង

## អត្ថប្រយោជន៍បន្ថែមការការពារ

(តទៅនេះហៅថា "អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម")

## I. និយមន័យ

១. "**សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ**" សំដៅទៅដល់សកម្មភាពដូចខាងក្រោមនេះ÷

(១) ការផ្ទេរកន្លែង - ការឡើង និងចុះពីកៅអីដោយពុំបាច់មានជំនួយពីអ្នកដទៃ។

(២) ការបំលាស់ទី - សមត្ថភាពក្នុងការផ្លាស់ទីពីបន្ទប់មួយទៅបន្ទប់មួយដោយពុំបាច់មានជំនួយពីអ្នកដទៃណាម្នាក់។

(៣) ការបន្ទោរបង់ - សមត្ថភាពក្នុងការគ្រប់គ្រងចលនាពោះវៀន និងប្លោកនោមដោយឆន្ទៈ ដូចជាដើម្បីការថែរក្សាអនាម័យផ្ទាល់ខ្លួនជាដើម។

(៤) ការស្លៀកពាក់ - ការពាក់ និងដោះសម្ភារៈចាំបាច់ទាំងអស់ដែលស្លៀកពាក់នៅជាប់រាងកាយដោយមិនត្រូវការជំនួយពីអ្នកដទៃ។

(៥) ការងូតទឹក ឬការលាងសម្អាតកាយ - សមត្ថភាពក្នុងការលាងសម្អាតកាយក្នុងបន្ទប់ទឹក ឬងូតទឹក (រួមទាំងការចូល ឬចេញពីបន្ទប់ទឹក ឬងូតទឹក) ឬលាងសម្អាតកាយដោយមធ្យោបាយផ្សេងទៀត។

(៦) ការបរិភោគអាហារ - គ្រប់កិច្ចការទាំងអស់ក្នុងការទទួលទានចំណីអាហារចូលក្នុងខ្លួននៅពេលដែលអាហារនោះត្រូវបានគេរៀបចំជូន។

២. "**បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន**" សំដៅទៅលើខ និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍ធានារ៉ាប់រងមូលដ្ឋាន ហើយត្រូវរាប់បញ្ចូលកិច្ចព្រមព្រៀង និង/ ឬ កិច្ចសន្យាបន្ថែមទាំងអស់ លើកលែងតែមានការកំណត់ជាក់លាក់ថាកិច្ចព្រមព្រៀង និង/ ឬ កិច្ចសន្យាបន្ថែមនោះមិនត្រូវបានចាត់បញ្ចូលជាផ្នែកនៃបណ្ណសន្យារ៉ាប់រងនេះ។

៣. "**អ្នកទទួលផល**" សំដៅដល់តតិយជននៃកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ដែលនឹងទទួលបានអត្ថប្រយោជន៍ ស្របច្បាប់ពីកិច្ចសន្យាធានារ៉ាប់រងនេះ។

៤. "**ច្បាប់នៃប្រទេសកម្ពុជា**" សំដៅដល់ច្បាប់ដែលមាន និងបទប្បញ្ញត្តិណាមួយ ឬទាំងអស់ដែលត្រូវបានដាក់ឱ្យអនុវត្តនៅប្រទេសកម្ពុជានិង/ ឬ រាល់វិសោធនកម្មដែលពាក់ព័ន្ធ។

៥. "**រយៈពេលសម្រេចចិត្ត**" សំដៅទៅលើរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃគិតចាប់ពីថ្ងៃដែលអ្នកបានទទួលបណ្ណសន្យារ៉ាប់រង។

៦. “**កិច្ចសន្យាធានារ៉ាប់រង**” សំដៅដល់កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ដែលធ្វើឡើងដោយ និងរវាងក្រុមហ៊ុន និងអ្នកត្រូវបានធានារ៉ាប់រង / ម្ចាស់បណ្ណសន្យារ៉ាប់រង។

៧. “**ការវះកាត់ដែលត្រូវបានធានារ៉ាប់រង**” សម្រាប់គោលបំណងនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ត្រូវមានន័យថាជាដំណើរការវះកាត់ ឬបែបបទផ្សេងៗដែលបានកំណត់ ឬបញ្ជាក់ក្នុងតារាងជំងឺធ្ងន់ធ្ងរ។

៨. “**អាការៈជំងឺធ្ងន់ធ្ងរ**” គឺជាពេលដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាទទួលរងគ្រោះពីជំងឺធ្ងន់ធ្ងរមួយ ឬពិតជាបានឆ្លងកាត់ការវះកាត់ដែលត្រូវបានធានារ៉ាប់រងសម្រាប់ជំងឺធ្ងន់ធ្ងរមួយដូចដែលមានកំណត់នៅក្នុងតារាងជំងឺធ្ងន់ធ្ងរ។

៩. “**ចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរ**” មានន័យថាជាចំណាត់ថ្នាក់នៃអាការៈជំងឺធ្ងន់ធ្ងរដូចមានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ។

១០. “**ការធ្វើរោគវិនិច្ឆ័យ**” មានន័យថាការធ្វើរោគវិនិច្ឆ័យជាក់លាក់ណាមួយដោយគ្រូពេទ្យ ដូចដែលបានកំណត់ខាងក្រោម ដោយផ្អែកទៅលើភស្តុតាងជាក់លាក់នោះ ដូចបានសំដៅដល់និយមន័យនៃអាការៈជំងឺធ្ងន់ធ្ងរជាក់លាក់ណាមួយ ឬនៅពេលអវត្តមានភស្តុតាងជាក់លាក់នោះ ដោយផ្អែកលើភស្តុតាងនៃវិទ្យុសាស្ត្រ គ្លីនិក ជាលិកាសាស្ត្រ ឬមន្ទីរពិសោធន៍ដែលបានទទួលស្គាល់ដោយយើងខ្ញុំ។ ការធ្វើរោគវិនិច្ឆ័យនេះ ត្រូវតែទទួលបានការគាំទ្រដោយគ្រូពេទ្យដែលបានចាត់តាំងដោយយើងខ្ញុំ ដែលគាត់អាចសម្អាងគំនិតរបស់គាត់លើភស្តុតាងវេជ្ជសាស្ត្រដែលបានដាក់ជូនដោយអ្នកត្រូវបានធានារ៉ាប់រង និង/ ឬ ភស្តុតាងបន្ថែមណាមួយដែលគ្រូពេទ្យអាចនឹងត្រូវការ។

ក្នុងករណីដែលមានជម្លោះ ឬភាពមិនយល់ស្របគ្នាពាក់ព័ន្ធនឹងភាពសមស្រប ឬភាពត្រឹមត្រូវនៃការធ្វើរោគវិនិច្ឆ័យនេះ យើងខ្ញុំត្រូវមានសិទ្ធិទាមទារឱ្យមានការពិនិត្យលើអ្នកត្រូវបានធានារ៉ាប់រង ឬលើភស្តុតាងដែលត្រូវបានប្រើប្រាស់រហូតដល់មានការធ្វើរោគវិនិច្ឆ័យនេះ ដោយអ្នកជំនាញឯករាជ្យក្នុងវិស័យសុខាភិបាលដែលពាក់ព័ន្ធ និងដែលត្រូវបានជ្រើសរើសដោយយើងខ្ញុំ ហើយគំនិតយោបល់របស់អ្នកជំនាញទៅលើការធ្វើរោគវិនិច្ឆ័យនោះ ត្រូវមានអនុភាពភ្ជាប់កាតព្វកិច្ចទាំងលើអ្នកត្រូវបានធានារ៉ាប់រង និង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង និងយើងខ្ញុំ។

១១. “**កាលបរិច្ឆេទចាប់ផ្តើមសុពលភាព**” ឬ “**កាលបរិច្ឆេទចាប់ផ្តើម**” គឺជាកាលបរិច្ឆេទដែលការធានារ៉ាប់រង ស្របតាមបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះ ឬបណ្ណសន្យារ៉ាប់រងដែលពាក់ព័ន្ធចូលជាធរមាន។ កាលបរិច្ឆេទចាប់ផ្តើមសុពលភាព ត្រូវបានបង្ហាញនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ហើយកាលបរិច្ឆេទចាប់ផ្តើម គឺជាកាលបរិច្ឆេទនៃការចេញកិច្ចព្រមព្រៀង និង/ ឬ កិច្ចសន្យាបន្ថែមនានា ដែលមានបង្ហាញក្នុងកិច្ចសន្យាបន្ថែមនីមួយៗនៅរាល់ពេលដែលខ និងលក្ខខណ្ឌដើមរបស់បណ្ណសន្យារ៉ាប់រងនេះ

ត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់។ កាលបរិច្ឆេទចាប់ផ្តើមក៏ជាកាលបរិច្ឆេទដែលទទួលបានការអនុញ្ញាតលើការបន្តសុពលភាពឡើងវិញនូវបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និង/ឬអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមក្នុងករណីដែលមានការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ។

១២. "**កាលបរិច្ឆេទផុតកំណត់**" សម្រាប់បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះ ឬអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម មានន័យថាជាកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះ ឬអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមត្រូវផុតកំណត់ ដូចមានបង្ហាញក្នុងតារាងនៃអត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រងដែលស្ថិតក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

១៣. "**រយៈពេលអនុគ្រោះ**" សំដៅទៅលើរយៈពេលអនុគ្រោះចំនួន ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដល់កំណត់ត្រូវបង់ នឹងត្រូវបានអនុញ្ញាតសម្រាប់ការបង់បុព្វលាភធានារ៉ាប់រងបន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងដំបូង។ បណ្ណសន្យារ៉ាប់រងនេះនឹងបន្តមានសុពលភាពអនុវត្តក្នុងអំឡុងរយៈពេលអនុគ្រោះនេះ។ ប្រសិនបើមានបុព្វលាភធានារ៉ាប់រងណាមួយមិនទាន់បានបង់នៅពេលផុតរយៈពេលអនុគ្រោះ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃកាលបរិច្ឆទផុតកំណត់នៃរយៈពេលអនុគ្រោះ។ ដូច្នេះបណ្ណសន្យារ៉ាប់រងត្រូវអស់សុពលភាព លើកលែងតែបណ្ណសន្យារ៉ាប់រងត្រូវបានបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ស្របតាមលក្ខខណ្ឌតម្រូវរបស់យើងខ្ញុំ។

១៤. "**អ្នកត្រូវបានធានារ៉ាប់រង**" សំដៅដល់បុគ្គលដែលត្រូវបានធានា និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង ហើយដែលឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនត្រូវបានបង្ហាញលើវិញ្ញាបនបត្រធានារ៉ាប់រង។

១៥. "**ការវះកាត់ / ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់**" មានន័យថាជាអាការៈជំងឺធ្ងន់ធ្ងរដែលមានស្ថានភាព ដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ។

១៦. "**ម្ចាស់បណ្ណសន្យារ៉ាប់រង**" សំដៅដល់បុគ្គល ដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រងនេះ។

១៧. "**អចិន្ត្រៃយ៍**" មានន័យថាការណ៍ដែលរំពឹងថាអាចស្ថិតនៅពេញមួយជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង។

១៨. "**បណ្ណសន្យារ៉ាប់រង**" សំដៅដល់បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមផ្សេងៗដែលអាចនឹងភ្ជាប់មកជាមួយបណ្ណសន្យារ៉ាប់រង។

១៩. "**ខួបនៃបណ្ណសន្យារ៉ាប់រង**" សំដៅដល់កាលបរិច្ឆេទដដែលៗជារៀងរាល់ឆ្នាំ ដូចនឹងកាលបរិច្ឆេទនៃបណ្ណសន្យារ៉ាប់រង។

២០. "**បំណុលបណ្ណសន្យារ៉ាប់រង**" គឺជាចំនួនទឹកប្រាក់សរុបដែលអ្នកជំពាក់យើងខ្ញុំក្រោមបណ្ណសន្យារ៉ាប់រងនេះ រួមទាំងប្រាក់ពិន័យដែលកើតមានឡើង។

២១. “**កាលបរិច្ឆេទនៃបណ្ណសន្យារ៉ាប់រង**” គឺជាកាលបរិច្ឆេទចូលជាធរមាននៃបណ្ណសន្យារ៉ាប់រង ដូចមានបង្ហាញក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ វាជាកាលបរិច្ឆេទដែលខួបបណ្ណសន្យារ៉ាប់រង ចំនួនឆ្នាំនៃបណ្ណសន្យារ៉ាប់រង ខែនៃបណ្ណសន្យារ៉ាប់រង និងកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង ត្រូវបានកំណត់។

២២. “**ឆ្នាំនៃបណ្ណសន្យារ៉ាប់រង**” សំដៅទៅរយៈពេល ១២ (ដប់ពីរ) ខែចន្លោះខួបចំនួន២ (ពីរ) នៃបណ្ណសន្យារ៉ាប់រង ។

២៣. “**ស្ថានភាពដែលមានពីមុនស្រាប់**” មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងនិង/ឬអ្នកបានដឹងច្បាស់អំពីវា។ អ្នកត្រូវបានធានារ៉ាប់រង និង/ឬអ្នក អាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានលក្ខខណ្ឌណាមួយដូចបានចែងខាងក្រោម÷

(១) អ្នកត្រូវបានធានារ៉ាប់រង និង/ឬអ្នកបានទទួល ឬកំពុងទទួលការព្យាបាល

(២) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

(៣) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

(៤) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

២៤. “**បុព្វលាភធានារ៉ាប់រង**” សំដៅទៅលើចំនួនទឹកប្រាក់ដែលអ្នកត្រូវបង់មកឲ្យក្រុមហ៊ុនតាមការកំណត់របស់ក្រុមហ៊ុននៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

២៥. “**កាលបរិច្ឆេទឈប់បង់បុព្វលាភធានារ៉ាប់រង**” សំដៅទៅលើកាលបរិច្ឆេទនៅពេលដែលម្ចាស់បណ្ណសន្យារ៉ាប់រងឈប់បង់បុព្វលាភក្រោមបណ្ណសន្យារ៉ាប់រងនេះទៅកាន់ក្រុមហ៊ុន ហើយកាលបរិច្ឆេទនេះមានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

២៦. “**គ្រូពេទ្យ**” មានន័យថាអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រដែលបានចុះបញ្ជីត្រឹមត្រូវ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវបានផ្តល់អាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈពេទ្យតាមបែបបស្ចិមប្រទេស និងអ្នកដែលប្រកបវិជ្ជាជីវៈក្នុងទំហំវិសាលភាពនៃអាជ្ញាបណ្ណដែលបានផ្តល់ឲ្យ និងឆ្លងកាត់ការបណ្តុះបណ្តាលក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ប៉ុន្តែលើកលែងចំពោះគ្រូពេទ្យ ឬគ្រូពេទ្យវះកាត់ដែលជាអ្នកត្រូវបានធានារ៉ាប់រង និង/ឬខ្លួនអ្នកផ្ទាល់។

២៧. “**អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម**” សំដៅទៅលើអត្ថប្រយោជន៍ ឬការធានារ៉ាប់រងបន្ថែមទៅលើបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន។ វាត្រូវបានដាក់ភ្ជាប់ជាមួយនឹងបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើឈ្មោះផលិតផល ឬកូដ និងលេខសម្គាល់ទម្រង់ឯកសារ មានបង្ហាញនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ឬក្រោយមកត្រូវបានដាក់បន្ថែមដោយកិច្ចព្រមព្រៀង និង/ឬ កិច្ចសន្យាបន្ថែមផ្សេងៗ។

២៨. **"ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង"** មានន័យថាជាចំនួនទឹកប្រាក់នៃការធានារ៉ាប់រងដែលបាន កំណត់នៅពេលចេញបណ្ណសន្យារ៉ាប់រង និងដែលត្រូវបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងត្រូវបានកែប្រែជាបន្តបន្ទាប់ទៅតាមខ និងលក្ខខណ្ឌនៃ បណ្ណសន្យារ៉ាប់រង ចំនួនទឹកប្រាក់ក្រោយការកែប្រែនេះនឹងក្លាយជាចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង។

២៩. **"ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍"** ឬ **"ពិការភាព"** មានន័យថាអ្នកត្រូវបានធានារ៉ាប់រង និង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងរងគ្រោះដោយការបាត់បង់ទាំងស្រុង និងដែលមិនអាចជាសះស្បើយឡើងវិញ បានជាអចិន្ត្រៃយ៍នូវ÷

- ដៃទាំងពីរ ឬ
- ជើងទាំងពីរ ឬ
- ដៃម្ខាង និងជើងម្ខាង ឬ
- ភ្នែកទាំងពីរ ឬ
- ភ្នែកម្ខាង និងដៃម្ខាង ឬ
- ភ្នែកម្ខាង និងជើងម្ខាង។

តាមរយៈនិយមន័យនេះ ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយឡើងវិញបានជាអចិន្ត្រៃយ៍នូវ÷

(ក) ភ្នែកម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់គ្រាប់ភ្នែក ឬពិការភ្នែកទាំងស្រុង

(ខ) ដៃម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់ចាប់ពីផ្នែកខាងលើនៃកដៃឡើងទៅ និង

(គ) ជើងម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់ចាប់ពីផ្នែកខាងលើនៃកជើងឡើងទៅ។

ក្នុងករណីបាត់បង់ដៃ ឬជើង ឬភ្នែកទាំងស្រុង លិខិតបញ្ជាក់អំពីការបាត់បង់នេះអាចត្រូវបានធ្វើឡើងនៅ ពេលណាក៏បានក្នុងអំឡុងរយៈពេលនៃការធានារ៉ាប់រង និងនាពេលដែលបណ្ណសន្យារ៉ាប់រងនៅមានសុពល ភាព។ តាមរយៈនិយមន័យនេះ ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយឡើងវិញបានជាអចិន្ត្រៃ យ៍នូវដៃម្ខាង ឬទាំងពីរ ឬជើងម្ខាង ឬទាំងពីរ ក៏មានន័យថាជាការបាត់បង់នូវមុខងារប្រើប្រាស់របស់ដៃ ម្ខាង ឬទាំងពីរ ឬជើងម្ខាង ឬទាំងពីរនោះដែរ ប្រសិនបើមានការបញ្ជាក់ត្រឹមត្រូវពីមន្ទីរពេទ្យ ដែលបាន ចុះបញ្ជីយ៉ាងហោចណាស់ត្រឹមថ្នាក់ខេត្តថាការបាត់បង់នោះកើតឡើងបន្ទាប់ពីថ្ងៃកំណើតឆ្នាំទី ១៨ (ដប់ ប្រាំបី) របស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង ហើយដែលស្ថានភាពពិការនេះ មានរយៈពេលយ៉ាងហោចណាស់ ៦ (ប្រាំមួយ) ខែ។

៣០. **"រយៈពេលរង់ចាំ"** សំដៅទៅលើរយៈពេលចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាព ឬកាលបរិច្ឆេទ នៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ រយៈពេលរង់ ចាំសម្រាប់ការវះកាត់/ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់មានរយៈពេល ៩០ (កៅសិប) ថ្ងៃ។

៣១. "**យើង**" "**យើងខ្ញុំ**" "**របស់យើងខ្ញុំ**" ឬ "**ក្រុមហ៊ុន**" សំដៅដល់ក្រុមហ៊ុន ជីស៊ី ឡាយហ្វ៍ អ៊ិនស្វូរេន ម.ក។

៣២. "**អ្នក**" ឬ "**របស់អ្នក**" សំដៅដល់ម្ចាស់បណ្ណសន្យារ៉ាប់រងដូចបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

នៅពេលណាដែលបរិបទតម្រូវ វាក្យស័ព្ទសំដៅមានភេទប្រុស អាចត្រូវបានអនុវត្តចំពោះវាក្យស័ព្ទភេទស្រីផងដែរ ហើយវាក្យស័ព្ទជាឯកវចនៈ អាចត្រូវរាប់បញ្ចូលទាំងវាក្យស័ព្ទជាពហុវចនៈដែរ។

## II. កម្មវត្ថុនៃការធានា

អាយុជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង។

## III. វិសាលភាពនៃការធានា

បណ្ណសន្យារ៉ាប់រងនេះផ្តល់ការការពារលើ មរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងការវះកាត់/ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

## IV. អត្ថប្រយោជន៍នៃការធានា

### ជម្រើសទី១÷ សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដូចដែលបានកំណត់ក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ក្នុងអំឡុងពេលដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះកំពុងមានសុពលភាព ក្រុមហ៊ុននឹងផ្តល់សំណងជូនអ្នក ឬអ្នកទទួលផល ទៅតាមករណីជាក់ស្តែងនូវចំនួន១០០% (មួយរយភាគរយ) នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ដោយដកមកវិញនូវបំណុលនានា ប្រសិនបើមាន។ បន្ទាប់មកអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះត្រូវបានបញ្ចប់។

### ជម្រើសទី២÷ សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬការវះកាត់/ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរ ឬទទួលការវះកាត់ជាក់ស្តែងណាមួយ ដូចដែលបានកំណត់ក្នុងតារាងនៃជំងឺធ្ងន់ធ្ងរក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ក្នុងអំឡុងពេលដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះកំពុងមានសុពលភាព ក្រុមហ៊ុននឹងផ្តល់សំណងជូនអ្នក ឬអ្នកទទួលផល ទៅតាមករណីជាក់ស្តែងនូវចំនួន១០០% (មួយរយភាគរយ) នៃទឹកប្រាក់ត្រូវ

បានធានារ៉ាប់រងនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ដោយដកមកវិញនូវបំណុលនានា ប្រសិនបើមាន។ បន្ទាប់មកអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះត្រូវបានបញ្ចប់។

នៅពេលផ្តល់ប្រាក់សំណង ឬកម្រៃណាមួយខាងលើ ប្រាក់ជំពាក់ណាមួយស្របតាមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ នឹងត្រូវដកចេញពីចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ស្របតាមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។

ខ និងលក្ខខណ្ឌទាំងនេះត្រូវជំនួសបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីនេះ ដែលអាចត្រូវបានភ្ជាប់ជាមួយ ឬដាក់ជាផ្នែកនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។

## V. ខ និងលក្ខខណ្ឌស្តីពីបុព្វលាភធានារ៉ាប់រង

### (១) ការបង់ប្រាក់

រាល់បុព្វលាភធានារ៉ាប់រងទាំងអស់ក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ត្រូវបង់មកឱ្យយើងខ្ញុំទៅតាមកាលបរិច្ឆេទដែលដល់កំណត់ត្រូវបង់ ឬមុនកាលបរិច្ឆេទដល់កំណត់ត្រូវបង់ តាមវិធីដែលយើងខ្ញុំកំណត់។ លិខិតតម្កល់ប្រាក់ដែលមានសុពលភាព ឬការកាត់បុព្វលាភធានារ៉ាប់រងចេញពីគណនីដែលបង្ហាញក្នុងរបាយការណ៍គណនីរបស់អ្នកត្រូវបានចាត់ទុកថាជាភស្តុតាងនៃការបានបង់ប្រាក់រួច។
មធ្យោបាយបង់បុព្វលាភនឹងត្រូវអនុវត្តតាមបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន។
បុព្វលាភធានារ៉ាប់រងនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ (សម្រាប់អត្ថប្រយោជន៍នៃការធានាជម្រើសទី២) អាចនឹងត្រូវធ្វើការផ្លាស់ប្តូរដោយយើងខ្ញុំ អាស្រ័យនឹងកត្តាមួយចំនួន ប៉ុន្តែមិនកំណត់ត្រឹមអាយុដែលបានកំណត់ មុខរបររបស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬម្ចាស់បណ្ណសន្យារ៉ាប់រង និងកម្រិតនៃអាការៈជំងឺធ្ងន់ធ្ងរដែលត្រូវបានធានាស្របតាមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ដោយយើងខ្ញុំនឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សររយៈពេល ៩០ (កៅសិប) ថ្ងៃមុនពេលការកែប្រែចាប់ផ្តើមមានសុពលភាព។

### (២) ការផ្លាស់ប្តូរ

អ្នកអាចផ្លាស់ប្តូរវិធីសាស្ត្របង់បុព្វលាភធានារ៉ាប់រងបាន ដោយដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំ។ អនុលោមតាមលក្ខខណ្ឌអប្បបរមានៃបុព្វលាភធានារ៉ាប់រងរបស់យើងខ្ញុំ បុព្វលាភធានារ៉ាប់រងអាចត្រូវបានបង់ជាប្រចាំឆ្នាំ ឬប្រចាំឆមាស ឬប្រចាំត្រីមាស ឬប្រចាំខែ តាមអត្រាដែលត្រូវអនុវត្តនៅកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង។
វិធីសាស្ត្របង់បុព្វលាភនឹងត្រូវអនុវត្តតាមបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន។

**(៣) ការបំពាន**

បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងលើកទី ១ (មួយ) ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងបន្ត បន្ទាប់នៅកាលបរិច្ឆេទដល់កាលកំណត់បង់ នឹងត្រូវបានចាត់ទុកជាការបំពានលក្ខខណ្ឌបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនទាន់បានបង់ បន្ទាប់ពីរយៈពេលអនុគ្រោះដល់កាលកំណត់ បណ្ណសន្យារ៉ាប់រងនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងមិនមានសុពលភាពក្នុងអំឡុងពេលនៃការផ្អាកសុពលភាពនេះឡើយ។

**(៤) ការកាត់កងបុព្វលាភធានារ៉ាប់រងនៅពេលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬការវះកាត់/ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់**

បន្ទាប់ពីអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ឬទទួលការវះកាត់ សមតុល្យណាមួយនៃបុព្វលាភធានារ៉ាប់រង ដែលដល់កំណត់បង់នៅពេលចុងបញ្ចប់នៃឆ្នាំនៃបណ្ណសន្យារ៉ាប់រង ដែលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ឬទទួលការវះកាត់នោះកើតឡើង ត្រូវដកចេញពីប្រាក់សំណងធានារ៉ាប់រងដែលត្រូវបង់ស្របតាមបណ្ណសន្យារ៉ាប់រងនេះ។

## VI. ករណីមិនធានា

អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះមិនធានាលើ៖

**១. មរណភាព**

មិនមានអត្ថប្រយោជន៍លើមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ។

(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។

(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

ក្រុមហ៊ុនមិនធានាលើការបាត់បង់ ឬពិការភាពដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម÷

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៤) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

(៥) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(៦) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។

(៧) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់

បណ្ណសន្យារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមាន ពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម÷

ក) អ្នកត្រូវបានធានារ៉ាប់រងនិង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល

ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

ឃ) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៨) អ្នកត្រូវបានធានារ៉ាប់រងនិង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

## ៣. ការវះកាត់/ ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

(១) ជំងឺដែលបណ្តាលមកពីជំងឺអេដស៍ ភាពស្មុគស្មាញទាក់ទងនឹងជំងឺអេដស៍ ឬការបង្ករោគដោយវីរុសហ៊ីវ(HIV)។

(២) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះមានសុពលភាព ឬកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រង និង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម÷

ក. អ្នកត្រូវបានធានារ៉ាប់រង និង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល

ខ. យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ. មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ

ឃ. វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៣) ការប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឱ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(៤) អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

(៥) ជំងឺធ្ងន់ធ្ងរទាំងអស់ដែលមានស្រាប់ ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយរាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូង ដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំ ហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។

(៦) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៧) ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល។ អ្នកទទួលផលដែលមិនបានចូលរួមពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសព្រហ្មទណ្ឌដែលបានរៀបរាប់ខាងលើ នឹងនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍របស់ពួកគេដដែល។

(៨) ប្រសិនបើមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីការសារធាតុវិទ្យុសកម្មដែលកើតឡើងពី ឥន្ធនៈ អាវុធ កាកសំណល់ ឬការកែច្នៃ។

(៩) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(១០) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

## VII. ទីតាំងភូមិសាស្ត្រនៃការធានា

ទូទាំងពិភពលោក។

## VIII. អ្នកទទួលផល

ម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នក ដែលក៏ជាអ្នកត្រូវបានធានារ៉ាប់រង អាចចាត់តាំងបុគ្គលណាម្នាក់ក្នុងការទទួលប្រាក់ដែលនឹងត្រូវបង់ជូននាពេលអ្នកទទួលមរណភាព។ អ្នកអាចកំណត់ឈ្មោះអ្នកទទួលផលម្នាក់ ឬច្រើននាក់ នៅពេលដាក់ពាក្យស្នើសុំ ឬនៅពេលណាមួយក៏បាន ក្រោយពេលដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះត្រូវបានចេញជូនក្នុងទម្រង់ស្នើសុំដែលបានកំណត់របស់យើងខ្ញុំ។

ដោយអនុលោមតាមច្បាប់ អ្នកមានសិទ្ធិក្នុងការដកហូតការតែងតាំងណាមួយ និង/ ឬ តែងតាំងអ្នកទទួលផលផ្សេងម្នាក់ ឬច្រើននាក់ផ្សេងទៀត ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សររបស់អ្នកត្រូវតែទទួលបាន និងកត់ត្រាដោយយើងខ្ញុំសម្រាប់អំឡុងពេលនៅរស់រានមានជីវិតរបស់អ្នក។

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានបំណងចង់ដកហូត ឬផ្លាស់ប្តូរអ្នកទទួលផលបច្ចុប្បន្នណាមួយដំបូង អ្នកត្រូវបានធានារ៉ាប់រងត្រូវតែក្លាយជាម្ចាស់បណ្ណសន្យារ៉ាប់រងជាមុនសិន។ បន្ទាប់មកតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំ និងដាក់ពាក្យស្នើសុំឲ្យបានត្រឹមត្រូវ អ្នកត្រូវបានធានារ៉ាប់រងអាចដំណើរការការដកហូត និងតែងតាំងអ្នកទទួលផលម្នាក់ ឬច្រើននាក់ផ្សេងទៀត។ ការដកហូត និងការផ្លាស់ប្តូរអ្នកទទួលផលណាមួយត្រូវមានប្រសិទ្ធិភាពចាប់ពីថ្ងៃដែលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរនោះបានប្រគល់មកដល់យើងខ្ញុំ។

ក្នុងករណីអ្នកបានតែងតាំងអ្នកទទួលផលលើសពីមួយនាក់ យើងខ្ញុំត្រូវផ្តល់ប្រាក់ដែលនឹងត្រូវបង់ទៅឲ្យបុគ្គលដែលទទួលបានការតែងតាំងដោយអ្នក ហើយនៅរស់រានមានជីវិតបន្ទាប់ពីមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងចំណែកស្មើៗគ្នា លើកលែងតែអ្នកបានកំណត់ផ្សេងពីនេះ។ ការបែងចែកនេះនឹងត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ជាធរមាននាពេលនោះ។

ការទូទាត់ប្រាក់នេះ នឹងត្រូវបានចាត់ទុកថាជាការដោះបន្ទុកនៃការបង់ប្រាក់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយពុំមានអ្នកទទួលផលណាម្នាក់ត្រូវបានតែងតាំង ឬអ្នកទទួលផលនោះបានទទួលមរណភាព ទឹកប្រាក់ទាំងនោះអាចនឹងត្រូវបង់ជូនសាច់ញាតិរបស់អ្នកទទួលផលនោះ។ ករណីនេះនឹងត្រូវអនុវត្តតាមច្បាប់ជាធរមាននាពេលនោះ។

## IX. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

កិច្ចសន្យាធានារ៉ាប់រងអាចត្រូវបានកែប្រែដោយយើង តាមរយៈកិច្ចសន្យាបន្ថែមបន្ទាប់ពីការវាយតម្លៃហានិភ័យធានារ៉ាប់រង ឬតាមការស្នើសុំរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងដើម្បីកែប្រែព័ត៌មានផ្ទាល់ខ្លួន ដូចជាលេខទូរស័ព្ទ អាសយដ្ឋាន ឬអ៊ីម៉ែល ឬព័ត៌មានផ្សេងៗដែលអាចស្នើសុំកែប្រែបាន។

ការកែប្រែណាមួយចំពោះកិច្ចសន្យាធានារ៉ាប់រងនឹងមានសុពលភាព នៅពេលដែលក្រុមហ៊ុនយល់ព្រមទទួលយកការកែប្រែ ហើយការកែប្រែនោះនឹងមានប្រសិទ្ធភាពចាប់ពីពេលដែលកិច្ចសន្យាបន្ថែមត្រូវបានចេញជូនដោយយើង និងប្រគល់ជូនអ្នកតាមរយៈអាសយដ្ឋានទំនាក់ទំនងចុងក្រោយដែលមាននៅក្នុងកំណត់ត្រារបស់យើង។

## X. ការបន្តកិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនត្រូវបានបង់បន្ទាប់ពីរយៈពេលអនុគ្រោះ ដែលបានកំណត់ខាងលើអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះអាចត្រូវបានដាក់បន្តសុពលភាពឡើងវិញតាមការសម្រេចរបស់យើងខ្ញុំ។ ប៉ុន្តែការដាក់បន្តសុពលភាពឡើងវិញនេះត្រូវធ្វើឡើងក្នុងរយៈពេល ២ (ពីរ) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទផ្អាកសុពលភាព និងក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១. ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំដាក់បន្តសុពលភាពអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះឡើងវិញ ។

២. អ្នកត្រូវបានធានារ៉ាប់រងនិង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងមានអាយុដែលអាចអនុញ្ញាតឱ្យទទួលការធានាបាន ដូចបានកំណត់ដោយយើងខ្ញុំនៅពេលដាក់បន្តសុពលភាពឡើងវិញ ។

៣. អ្នកត្រូវបានធានារ៉ាប់រងនិង/ ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបង្ហាញភស្តុតាងនៃភាពអាចធានារ៉ាប់រងបាន ដូចបានកំណត់ដោយយើងខ្ញុំនៅពេលដាក់បន្តសុពលភាពឡើងវិញ ។

៤. ការទូទាត់រាល់បុព្វលាភធានារ៉ាប់រងដែលហួសពេលកំណត់បង់ ជាមួយនឹងប្រាក់ពិន័យក្នុងអត្រាដែលកំណត់ដោយយើងនៅពេលហួសពេលកំណត់។

៥. ការទូទាត់បំណុលដែលមិនទាន់បានទូទាត់នៅពេលដែលពាក់ព័ន្ធ ជាមួយនឹងប្រាក់ពិន័យក្នុងអត្រាដែលកំណត់ដោយយើងខ្ញុំ និង

៦. ខ និងលក្ខខណ្ឌដទៃផ្សេងទៀតដែលយើងខ្ញុំអាចនឹងដាក់នៅពេលដែលពាក់ព័ន្ធ។

នៅពេលដាក់បន្តសុពលភាពឡើងវិញ អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនឹងត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញនោះ។ ប្រាក់ពិន័យលើបុព្វលាភធានារ៉ាប់រង និងបំណុលដែលកើតចេញពីបណ្ណសន្យារ៉ាប់រង (ប្រសិនបើមាន) នឹងត្រូវគិតបញ្ចូលគ្នារហូតដល់កាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ក្នុងអត្រាប្រចាំឆ្នាំដែលបានកំណត់ដោយយើងខ្ញុំ។ គ្មានការធានារ៉ាប់រងត្រូវបានផ្តល់ជូនស្របតាមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះក្នុងអំឡុងពេលដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមផ្អាកសុពលភាព រហូតដល់កាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញឡើយ។

ការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញណាមួយ ត្រូវធានារ៉ាប់រងតែលើការបាត់បង់ ឬព្រឹត្តិការណ៍ត្រូវបានធានារ៉ាប់រងដែលកើតឡើង បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញប៉ុណ្ណោះ។

## XI. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

អ្នកមានសិទ្ធិក្នុងការបញ្ចប់អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកយើងខ្ញុំ។ ប្រសិនបើអ្នកស្នើសុំបញ្ចប់អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ នៅក្នុងរយៈពេលសម្រេចចិត្ត យើងខ្ញុំនឹងផ្តល់ត្រឡប់ជូនអ្នកវិញនូវបុព្វលាភធានារ៉ាប់រងដែលអ្នកបានបង់ បន្ទាប់ពីធ្វើការទូទាត់ជាមួយនឹងចំណាយនានាពាក់ព័ន្ធនឹងការពិនិត្យសុខភាព។ បន្ទាប់ពីយើងខ្ញុំបានបង់ត្រឡប់បុព្វលាភធានារ៉ាប់រង អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះនឹងត្រូវបញ្ចប់ ហើយរាល់អត្ថប្រយោជន៍ និងសិទ្ធិដែលមានក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ នឹងត្រូវបានបញ្ចប់ និងគ្មានប្រសិទ្ធភាពតទៅទៀតនោះទេ។ ប្រសិនបើអ្នកស្នើសុំបញ្ចប់អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ បន្ទាប់ពីផុតរយៈពេលសម្រេចចិត្ត អ្នកនឹងពុំទទួលបានតម្លៃសាច់ប្រាក់នោះទេ ហើយបណ្ណសន្យារ៉ាប់រងនេះត្រូវបញ្ចប់ រួមទាំងសិទ្ធិ និងអត្ថប្រយោជន៍ដែលស្របតាមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះក៏ត្រូវបញ្ចប់ដែរ។

## XII. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមរបស់អ្នកនឹងត្រូវបានលុបចោលដោយស្វ័យប្រវត្តិ នៅពេលករណីណាមួយដូចខាងក្រោមកើតឡើង÷

(១) បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋានត្រូវបានលុបចោល ឬអត្ថប្រយោជន៍ដូចមានកំណត់នៅក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះត្រូវបានទូទាត់រួចរាល់ទាំងស្រុង។

(២) អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះដល់កាលកំណត់ ឬផុតកំណត់រយៈពេលនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញដូចបានចែងនៅក្នុងប្រការ X ឬបណ្ណសន្យារ៉ាប់រងត្រូវបានបញ្ចប់ដូចមានចែងនៅក្នុងប្រការ XI ខាងលើ។

ការទូទាត់ ឬការទទួលយកបុព្វលាភធានារ៉ាប់រងណាមួយបន្ទាប់ពីការលុបចោលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ នឹងមិនបង្កើតជាទំនួលខុសត្រូវណាមួយមកលើភាគីខាងយើងខ្ញុំឡើយ ប៉ុន្តែយើងខ្ញុំនឹងសងត្រលប់នូវបុព្វលាភធានារ៉ាប់រងដែលបានបង់នោះវិញ។

## XIII. ការទាមទារសំណង

### ១. ការជូនដំណឹងអំពីការទាមទារសំណង

ការជូនដំណឹងអំពីការទាមទារសំណងមកកាន់យើងខ្ញុំត្រូវធ្វើឡើងភ្លាមៗ តាមគ្រប់មធ្យោបាយ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃបន្ទាប់ពីថ្ងៃដែលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ឬមានអាការៈជំងឺធ្ងន់ធ្ងរ។ ការជូនដំណឹងនេះនឹងត្រូវចាត់ទុកថាបានជូនដំណឹង នៅពេលធ្វើការជូនដំណឹងមកការិយាល័យរបស់យើងខ្ញុំដោយភ្ជាប់មកជាមួយនូវព័ត៌មានគ្រប់គ្រាន់សម្រាប់កំណត់អត្តសញ្ញាណអ្នកត្រូវបានធានារ៉ាប់រង និង/ឬម្ចាស់បណ្ណសន្យារ៉ាប់រង។ ប្រសិនបើអ្នកទាមទារសំណងខកខានក្នុងការជូនដំណឹងភ្លាមៗ យើងខ្ញុំនឹងមិនបដិសេធការទាមទារសំណងណាមួយឡើយ ប្រសិនបើយើងខ្ញុំត្រូវបានពន្យល់បង្ហាញដោយសមហេតុផលថា អ្នកទាមទារសំណងពុំមានលទ្ធភាពក្នុងការជូនដំណឹងភ្លាមៗតាមរយៈពេលកំណត់ ហើយអ្នកទាមទារសំណងនោះបានព្យាយាមធ្វើការជូនដំណឹងនេះលឿនបំផុតតាមដែលអាចធ្វើបាន។

### ២. ភស្តុតាងនៃមរណភាព

នៅពេលបានទទួលការជូនដំណឹងនេះ យើងខ្ញុំនឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំសម្រាប់បំពេញដើម្បីជាភស្តុតាងនៃមរណភាព។ ប្រសិនបើទម្រង់ពាក្យស្នើសុំមិនត្រូវបានប្រគល់ឱ្យក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ អ្នកទាមទារសំណងត្រូវបានចាត់ទុកថាបានអនុវត្តតាមការតម្រូវនៃខនិងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សររៀបរាប់អំពីព្រឹត្តិការណ៍និងកាលៈទេសៈនៃការទទួលមរណភាពសម្រាប់សំណងដែលបានទាមទារ។

### ៣. ភស្តុតាងនៃពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ភស្តុតាងបង្ហាញអំពីពិការភាពត្រូវដាក់ជូនយើងខ្ញុំ ដែលយើងខ្ញុំជាអ្នកមានសិទ្ធិក្នុងការសម្រេចថាពិការភាពនោះគ្រប់លក្ខខណ្ឌដូចបានកំណត់នៅក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។ យើងខ្ញុំមានសិទ្ធិស្នើឱ្យមានការពិនិត្យ អ្នកត្រូវបានធានារ៉ាប់រង និង/ឬម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ ពិនិត្យលើភស្តុតាងបង្ហាញពីមូលហេតុដែលនាំឱ្យឈានដល់ពិការភាពនោះ ដោយបុគ្គលដែលជ្រើសរើសដោយយើងខ្ញុំ។

### ៤. ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ

នៅពេលទទួលបានការជូនដំណឹងនេះ យើងខ្ញុំនឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំសម្រាប់បំពេញដើម្បីជាភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ។ ប្រសិនបើទម្រង់ពាក្យស្នើសុំមិនត្រូវបានប្រគល់ឱ្យក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្រោយពីទទួលបានលិខិតជូនដំណឹងនេះទេ អ្នកទាមទារ

សំណងត្រូវបានចាត់ទុកថាបានអនុលោមតាមការតម្រូវនៃ ខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សរស្តីពីការកើតឡើងនៃអាការៈជំងឺធ្ងន់ធ្ងរ លក្ខណៈ និងកម្រិតនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានធ្វើការទាមទារសំណងនោះ។

ក) ប្រសិនបើមានការទាមទារសំណងចំនួន២(ពីរ) ឬច្រើនជាងនេះស្របតាមចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរក្នុងកម្រិតផ្សេងៗគ្នាដែលត្រូវបានធ្វើរោគវិនិច្ឆ័យឃើញក្នុងពេលដំណាលគ្នា យើងខ្ញុំនឹងធ្វើការទូទាត់ជូនតែមួយករណីប៉ុណ្ណោះ នូវចំនួនអត្ថប្រយោជន៍ណាដែលអាចទាមទារសំណងបានច្រើនជាងគេបំផុតដែលអនុម័តដោយយើងខ្ញុំ។

ខ) ការដាក់ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ

ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ ត្រូវប្រគល់ឲ្យយើងខ្ញុំក្នុងអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងនៅមានជីវិត និងក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យនៃអាការៈជំងឺធ្ងន់ធ្ងរនេះ។

**៥. ការទូទាត់សំណង**

បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់ឯកសារពាក់ព័ន្ធនឹងការទាមទារសំណងរួច ប្រសិនបើត្រូវបានបញ្ជាក់ថាត្រូវធ្វើការទូទាត់សង នោះយើងខ្ញុំនឹងទូទាត់សំណងជូនក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការទាមទារសំណងត្រូវបានអនុម័តដោយយើងខ្ញុំ។

**៦. របៀបទូទាត់សំណង**

ការទូទាត់សំណងអាចត្រូវបានធ្វើឡើងតាមរបៀបផ្សេងៗដូចជា ការផ្ទេរប្រាក់តាមគណនីធនាគារ មូលប្បទានបត្រ សាច់ប្រាក់ និងរបៀបទូទាត់ផ្សេងៗទៀតដែលអាចអនុវត្តបាននៅពេលទូទាត់។

## XIV. ការរក្សាព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឱ្យភាគីទីបីណាមួយដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឱ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

## XV. ការផ្សះផ្សាវិវាទ និងដែនយុត្តាធិការ

បណ្ណសន្យារ៉ាប់រងនេះត្រូវបានគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើជម្លោះណាមួយកើតចេញពី ឬពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះមិនអាចដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីដែលជាជម្រើសដំបូងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង គូភាគីយល់ព្រមដោយសុចរិតក្នុង

ការដោះស្រាយជម្លោះនេះតាមរយៈការសម្របសម្រួលពីនិយ័តករធានារ៉ាប់រងកម្ពុជា មុននឹងបញ្ជូនទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចផ្តាច់មុខ។

## XVI. បទប្បញ្ញត្តិទូទៅ

### ១. បណ្ណសន្យារ៉ាប់រង

អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ត្រូវបានផ្តល់ជូនជាតម្លៃតបស្នងទៅនឹងការបង់បុព្វលាភធានារ៉ាប់រង ដូចបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងអនុលោមតាម÷

- ក) ចម្លើយដែលបានផ្តល់ដោយអ្នក និងឬ អ្នកត្រូវបានធានារ៉ាប់រង ក្នុងទម្រង់ពាក្យស្នើ ឬទម្រង់សំណើសុំរបស់អ្នក ឬកម្រងសំណួរដែលយើងខ្ញុំផ្តល់នៅពេលក្រោយៗពាក់ព័ន្ធនឹងសំណើរបស់អ្នក និងព័ត៌មានណាមួយដែលផ្តល់ដោយអ្នក ក្នុងចន្លោះពេលរវាងការដាក់ពាក្យស្នើសុំ ឬសំណើ និងពេលដែលកិច្ចសន្យានេះត្រូវបានបង្កើតឡើង និង
- ខ) របាយការណ៍សុខភាព និងរបាយការណ៍ផ្សេងៗ ព្រមទាំងកម្រងសំណួរផ្សេងៗទៀត (ដែលហៅរួមគ្នាថា "ឯកសារព័ត៌មាន")

ហើយឯកសារព័ត៌មាននេះត្រូវក្លាយជាផ្នែកមួយនៃកិច្ចសន្យាធានារ៉ាប់រងរវាងយើងខ្ញុំ និងអ្នក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្នុងករណីមានការផ្តល់ព័ត៌មានមិនពិតណាមួយនៅមុនពេលចុះកិច្ចសន្យាពាក់ព័ន្ធនឹងឯកសារព័ត៌មាននេះ មានតែសំណងដែលផ្តល់ជូនតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះដែលនឹងត្រូវបានយកមកអនុវត្ត។

បណ្ណសន្យារ៉ាប់រងរបស់អ្នករួមមាន បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមដែលអាចនឹងត្រូវបានភ្ជាប់ជាមួយ។ ឈ្មោះផលិតផលនៃបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និងឬ ឈ្មោះកូដ និងឬឈ្មោះផលិតផល និងលេខទម្រង់នៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមប្រសិនបើមានភ្ជាប់មកជាមួយបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបានបង្ហាញនៅក្នុងតារាងអត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រងនៃវិញ្ញាបនបត្រធានារ៉ាប់រង។

### ២. រូបិយបណ្ណ និងរបៀបបង់ប្រាក់

រាល់ទឹកប្រាក់ដែលត្រូវបង់ឱ្យយើងខ្ញុំ ឬដោយយើងខ្ញុំ ត្រូវជារូបិយបណ្ណដែលមានបង្ហាញលើវិញ្ញាបនបត្រធានារ៉ាប់រង ឬការព្រមព្រៀងបន្តបន្ទាប់ទៀត។ រាល់ទឹកប្រាក់ដែលយើងខ្ញុំត្រូវបង់ ត្រូវធ្វើឡើងតាមរបៀបដែលកំណត់ដោយយើងខ្ញុំ។

## ៣. បទប្បញ្ញត្តិលើទិន្នន័យដែលតម្រូវ

ក) រាល់ព័ត៌មានផ្ទាល់ខ្លួនដែលយើងខ្ញុំបានប្រមូល ឬកាន់កាប់ដែលទាក់ទងនឹងអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ក្រោមបណ្ណសន្យារ៉ាប់រងនេះ អាចនឹងត្រូវបានប្រើប្រាស់ និងបង្ហាញដោយយើងខ្ញុំចំពោះបុគ្គល ឬអង្គការដែលពាក់ព័ន្ធជាមួយយើងខ្ញុំសម្រាប់បញ្ហាដែលទាក់ទងនឹងការធានារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រង។

ខ) វាគឺជាទំនួលខុសត្រូវរបស់អ្នក ក្នុងការធានាថាព័ត៌មានផ្ទាល់ខ្លួនដែលបានផ្តល់ជូនយើងខ្ញុំត្រូវមានភាពត្រឹមត្រូវច្បាស់លាស់។ អ្នកត្រូវទទួលខុសត្រូវសងសំណង និងបន្តទទួលខុសត្រូវសងសំណងមកយើងខ្ញុំ ចំពោះរាល់ការខាតបង់ថ្លៃសេវា ការចំណាយ សកម្មភាពនានាដែលយើងខ្ញុំបានទទួលរងគ្រោះ ដែលជាលទ្ធផលនៃការធ្វេសប្រហែសរបស់អ្នកក្នុងការអនុវត្តតាមខ និងលក្ខខណ្ឌខាងលើ។

## ៤. ការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និងឬភេទ

ក) អាយុដែលមានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងគឺជាអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងដែលបានប្រកាសក្នុងពាក្យស្នើសុំធានារ៉ាប់រងរបស់អ្នក។ អាយុដែលបានលើកឡើងខាងដើមនេះ គឺសំដៅអាយុគិតត្រឹមថ្ងៃកំណើតចុងក្រោយរបស់អ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងនៅកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

ក្នុងករណីមានការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និងឬ ភេទ បុព្វលាភធានារ៉ាប់រង និងឬ អត្ថប្រយោជន៍ដែលត្រូវបង់ នឹងត្រូវកែសម្រួលដោយយោងទៅតាមអាយុ និងឬ ភេទពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង។

ក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំដំបូងនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ប្រសិនបើយើងរកឃើញថានៅថ្ងៃដាក់ពាក្យស្នើសុំ អាយុពិតរបស់អ្នកត្រូវបានធានារ៉ាប់រងបែរជាមានអាយុច្រើនជាង ឬតិចជាងអាយុដាក់ពាក្យស្នើសុំដែលបានកំណត់ យើងមានសិទ្ធិបញ្ចប់នូវអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ និងផ្តល់ត្រឡប់នូវបុព្វលាភដែលអ្នកបានបង់ទៅឱ្យវិញ។

ខ) ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងមិនមានសិទ្ធិក្នុងការទទួលបានការធានារ៉ាប់រងទៅតាមអាយុ និងឬ ភេទពិតប្រាកដ អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះនឹងត្រូវចាត់ទុកជាមោឃៈ ហើយយើងខ្ញុំនឹងបង្វិលសងជូនអ្នកវិញនូវបុព្វលាភដែលបានបង់។

គ) ការបង់ជូននូវអត្ថប្រយោជន៍ក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះនឹងត្រូវបានធ្វើឡើង តែក្នុងករណីអាយុ និងឬ ភេទរបស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបានផ្ទៀងផ្ទាត់ និងបញ្ជាក់ថាត្រឹមត្រូវ។ អាយុ និងឬ ភេទរបស់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់

បណ្ណសន្យារ៉ាប់រងនឹងត្រូវបានផ្ទៀងផ្ទាត់ និងបញ្ជាក់ថាត្រឹមត្រូវ ប្រសិនបើមានភស្តុតាងជាក់លាក់ប្រគល់មកឱ្យយើងខ្ញុំ។

**៥. ភាពមិនអាចជំទាស់បាន**

ការខកខានរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងក្នុងការប្រកាសបង្ហាញពីចំណុចណាមួយ ឬការថ្លែងមិនពិតរបស់ពួកគេពីចំណុចណាមួយដែលខ្លួនបានយល់ដឹងថាជាចំណុចសំខាន់សម្រាប់ការធានារ៉ាប់រង (ហើយដែលមិនបានប្រកាសបង្ហាញដោយភាគីណាផ្សេងទៀត) តែមិនមានលក្ខណៈជាការបន្លំ នោះមិនអាចជាមូលហេតុនាំឱ្យក្រុមហ៊ុនចាត់ទុកអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះជាមោឃៈបានទេ បន្ទាប់ពីអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះបានមានសុពលភាពអស់រយៈពេល ២ (ពីរ) ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាព ឬកាលបរិច្ឆេទចាប់ផ្តើម ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបង្អស់។

ការខកខានក្នុងការប្រកាសបង្ហាញ ឬ ការថ្លែងមិនពិតអាចកើតមានឡើងលើពាក្យស្នើសុំធានារ៉ាប់រង ទម្រង់បែបបទភស្តុតាងពិនិត្យសុខភាពនានា ឬរបាយការណ៍ និងចម្លើយជាលាយលក្ខណ៍អក្សរណាមួយដែលផ្តល់ជាភស្តុតាងនៃភាពអាចធានារ៉ាប់រងបាន។

## XVII. បទប្បញ្ញត្តិស្តីពីភាពជាម្ចាស់បណ្ណសន្យារ៉ាប់រង

**(១) ម្ចាស់បណ្ណសន្យារ៉ាប់រង**

អ្នកជាម្ចាស់នៃបណ្ណសន្យារ៉ាប់រងនេះ ដូចដែលមានបង្ហាញក្នុងវិញ្ញាបនបត្រធានារ៉ាប់រង រហូតដល់មានការផ្លាស់ប្តូរផ្សេងពីនេះ។ ក្នុងអំឡុងពេលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងនៅរស់រានមានជីវិត ក្នុងនាមជាម្ចាស់បណ្ណសន្យារ៉ាប់រង មានតែអ្នកប៉ុណ្ណោះដែលមានសិទ្ធិអនុវត្តរាល់សិទ្ធិឯកសិទ្ធិ និងជម្រើសដែលផ្តល់ជូនក្រោមបណ្ណសន្យារ៉ាប់រងនេះ ដោយអនុលោមតាមការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកតំណាង និង សិទ្ធិរបស់អ្នកទទួលសិទ្ធិ (អនុប្បទានិក) ប្រសិនបើមាន។ ពេលអ្នកទទួលមរណភាព សិទ្ធិ ឯកសិទ្ធិ និងជម្រើសទាំងនេះត្រូវផ្ទេរឱ្យម្ចាស់បណ្ណសន្យារ៉ាប់រងបម្រុងប្រសិនបើមាន។

**(២) ការផ្លាស់ប្តូរម្ចាស់បណ្ណសន្យារ៉ាប់រង និងអនុប្បទាន**

ក្នុងអំឡុងពេលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះមានសុពលភាព អ្នកអាចផ្លាស់ប្តូរម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកទទួលផលបានដោយដាក់ជូននូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការផ្លាស់ប្តូរនេះមានសុពលភាព ប្រសិនបើត្រូវបានកត់ត្រាដោយយើងខ្ញុំក្នុងអំឡុងពេលអ្នកត្រូវបានធានារ៉ាប់រង

និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងនៅរស់រានមានជីវិត និងត្រូវបានយល់ព្រមលើអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះតែប៉ុណ្ណោះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវលើសុពលភាពនៃអនុប្បទានណាមួយឡើយ។ រាល់អនុប្បទានទាំងអស់ត្រូវធ្វើឡើង ដោយអាស្រ័យលើស្ថានភាពបំណុលដែលកើតមានក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។

## XVIII. បទប្បញ្ញត្តិផ្សេងៗទៀត

(១) ការបំពានលើច្បាប់ ការអស់សុពលភាព ឬភាពមិនអាចអនុវត្តបាននៃប្រការណាមួយក្នុងខ និងលក្ខខណ្ឌទូទៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នឹងមិនត្រូវប៉ះពាល់ដល់ប្រសិទ្ធិភាពនៃច្បាប់ ឬភាពដែលអាចអនុវត្តបាននៃបទប្បញ្ញត្តិផ្សេងទៀតដូចមានកំណត់នៅក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះឡើយ។

(២) បញ្ជីឯកសារ និងឬ គណនីរបស់យើងខ្ញុំគឺជាភស្តុតាងចុងក្រោយអំពីស្ថានភាពគណនីរវាងគូភាគីក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។ ការបញ្ជាក់ណាមួយរបស់បុគ្គលិកយើងខ្ញុំពាក់ព័ន្ធនឹងទឹកប្រាក់ ឬការទទួលខុសត្រូវនាពេលបច្ចុប្បន្នដែលមិនទាន់បានបង់ ឬនៅសល់ ដែលយើងខ្ញុំបានចំណាយសម្រាប់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជាប់ជាកាតព្វកិច្ច និងចាត់ទុកជាភស្តុតាងសំខាន់និងចុងក្រោយសម្រាប់អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងតុលាការគ្រប់ជាន់ថ្នាក់និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។

(៣) ប្រសិនបើយើងខ្ញុំពន្យារពេល ឬខកខានក្នុងការអនុវត្តសិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ណាមួយក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ នឹងមិនត្រូវចាត់ទុកជាការបោះបង់ចោលឡើយ។ ការអនុវត្តសិទ្ធិ ឬដំណោះស្រាយផ្លូវច្បាប់តែមួយ ឬដោយផ្នែក មិនអាចរារាំងយើងខ្ញុំពីការអនុវត្តសិទ្ធិ ឬដំណោះស្រាយតាមស្រាយផ្លូវច្បាប់ណាផ្សេងទៀតបានឡើយ។ សិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ផ្តល់ឲ្យក្នុងបណ្ណសន្យារ៉ាប់រងនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ត្រូវបូកបន្ថែម និងរាប់បញ្ចូលទាំងសិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ផ្សេងទៀត (មិនថាផ្តល់ឲ្យដោយច្បាប់ ឬផ្សេងពីនេះ)។

(៤) អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះត្រូវបន្តមានសុពលភាព និងចងភ្ជាប់ជាកាតព្វកិច្ចសម្រាប់រាល់គោលបំណងទាំងអស់ ទោះមានការផ្លាស់ប្តូរណាមួយដូចជាការរំលាយបញ្ចូលគ្នា ការផ្លាស់ប្តូរឈ្មោះ ការស្ថាបនាឡើងវិញ ឬផ្សេងពីនេះ ដែលអាចនឹងត្រូវបានធ្វើឡើងក្រោមការកំណត់របស់យើងខ្ញុំ។

(៥) ខ និងលក្ខខណ្ឌដែលបានចែងក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះបង្កើតបានជាខ និងលក្ខខណ្ឌទាំងមូលរបស់អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។ រាល់ការធានាអះអាង ឬការរាយការណ៍ផ្ទុយពីនេះពីមុនណាមួយធ្វើឡើងពាក់ព័ន្ធនឹងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ ទោះដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ មិនត្រូវបានចាត់ទុកជាផ្នែកនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះឡើយ។

(៦) យើងខ្ញុំរក្សាសិទ្ធិក្នុងការកែប្រែខ និងលក្ខខណ្ឌនៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ តាមវិធីនិងហេតុផលដែលយើងខ្ញុំគិតថាសមស្រប ក្នុងករណីមានការផ្លាស់ប្ដូរណាមួយក្នុងច្បាប់ ឬតាមគោលការណ៍នៃការប្រមូលពន្ធដែលត្រូវអនុវត្តចំពោះយើងខ្ញុំ ឬចំពោះអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះ។

## XIX. តារាងជំងឺធ្ងន់ធ្ងរ

### និយមន័យនៃជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

| | |
|---|---|
| **១. ជំងឺមហារីក** – នៃកម្រិតធ្ងន់ធ្ងរជាក់លាក់ និងមិនរាប់បញ្ចូលនូវមហារីកដំណាក់កាលដំបូងឡើយ | រាល់ដុំសាច់កាចដែលបានធ្វើរោគវិនិច្ឆ័យឃើញវិជ្ជមាន ដោយមានការបញ្ជាក់ដោយជាលិកាសាស្ត្រ និងកំណត់លក្ខណៈដោយការលូតលាស់មិនអាចគ្រប់គ្រងបាននៃកោសិកាកាច និងការរាតត្បាត/រាលដាលលើជាលិកាផ្សេងទៀត។ ពាក្យថាដុំសាច់កាចរួមបញ្ចូលផងដែរនូវ ជំងឺមហារីកគ្រាប់ឈាមស សាច់ដុះក្នុងជាលិកាក្រពេញទឹករងៃប្រភេទឡាំផូម៉ា និងមហារីកជាលិកាភ្ជាប់ប្រភេទសារកូម៉ា។<br>ចំពោះនិយមន័យខាងលើ មិនរួមបញ្ចូលអាការៈខាងក្រោមនេះទេ÷<br>(១) មហារីកទាំងអស់ដែលត្រូវបានចាត់ថ្នាក់តាមជាលិកាសាស្ត្រដូចខាងក្រោម÷<br>- មិនទាន់វិវត្តជាមហារីកកាច<br>- ដែលមិនរាតត្បាត ឬរាលដាល<br>- ជាលិកាមហារីកនៅទីតាំងដើម<br>- ដុំមហារីកដែលមិនទាន់មានការសាយភាយ<br>- ដុំដែលមានសក្ដានុពលអាចវិវត្តជាមហារីកកាច<br>(២) ដុំសាច់នៃក្រពេញប្រូស្តាតទាំងអស់ ដែលបានចំណាត់ថ្នាក់តាមជាលិកាសាស្ត្រ ធី១អ៊ិន០អ៊ឹម០ (ចំណាត់ថ្នាក់ដុំសាច់ ធីអ៊ិនអ៊ឹម)<br>(៣) ដុំសាច់នៃក្រពេញទីរ៉ូអ៊ីតទាំងអស់ ដែលបានចំណាត់ថ្នាក់តាមជាលិកាសាស្ត្រ ធី១អ៊ិន០អ៊ឹម០ (ចំណាត់ថ្នាក់ដុំសាច់ ធីអ៊ិនអ៊ឹម)<br>(៤) ដុំសាច់នៃប្លោកនោមទាំងអស់ ដែលបានចំណាត់ថ្នាក់តាមជាលិកាសាស្ត្រ ធី១អ៊ិន០អ៊ឹម០ (ចំណាត់ថ្នាក់ដុំសាច់ ធីអ៊ិនអ៊ឹម)<br>(៥) ជំងឺមហារីកគោលិកាសឡាំផូស៊ីតរ៉ាំរ៉ៃនៅក្រោមដំណាក់កាលទី៣ នៃការធ្វើចំណាត់ថ្នាក់តាមប្រព័ន្ធរ៉ៃ។<br>(៦) ជំងឺមហារីកទាំងអស់ដែលមានផ្ទុកមេរោគអេដស៍ (ហ៊ីវ) |

| | |
|---|---|
| | (៧) ជំងឺមហារីកស្បែកទាំងអស់លើកលែងតែមហារីកកាចកោសិកាបញ្ចេញជាតិមេឡានីន។ |
| **២. ជំងឺគាំងបេះដូង** | ការខូចសាច់ដុំបេះដូងដោយសារការផ្គត់ផ្គង់ឈាមទៅចិញ្ចឹមបេះដូងមិនគ្រប់គ្រាន់បង្កឲ្យមានការខូចសាច់ដុំបេះដូងស្រួចស្រាល់៖<br>(១) ប្រវត្តិនៃការឈឺទ្រូងជាប្រចាំ<br>(២) ការផ្លាស់ប្ដូរលក្ខណៈចរន្តអគ្គិសនីបេះដូងថ្មីមួយចំនួនដូចជា៖ ការកើនឡើង ឬស្រុតចុះនៃចរន្តអេសធី ការប្រែប្រួលរលកចរន្តធី រលកចរន្តឃ្យូបង្កដោយសារជំងឺ ឬការស្ទះមែកខាងឆ្វេងនៃសរសៃដែលនាំចរន្តអគ្គិសនីទៅកាន់បេះដូង និង<br>(៣) ការកើនឡើងរូបធាតុជីវៈបេះដូង រួមទាំងស៊ីភីខេអឹមប៊ី លើសកម្រិតធម្មតារបស់មន្ទីរពិសោធន៍ ឬប្រូតេអ៊ីនត្រូផូនីន ដែលបានកត់ត្រាក្នុងកម្រិតដូចខាងក្រោម ឬខ្ពស់ជាង៖ ប្រូតេអ៊ីនត្រូផូនីនបេះដូងប្រភេទធី ឬ ប្រូតេអ៊ីនត្រូផូនីនបេះដូងប្រភេទ អាយ ≥ ០,៥ ng/ml។<br>ភស្តុតាងបានបង្ហាញពីការខូចសាច់ដុំបេះដូងស្រួចស្រាល់ដោយសារការផ្គត់ផ្គង់បរិមាណឈាមទៅចិញ្ចឹមបេះដូងមិនគ្រប់គ្រាន់ហើយតម្រូវឲ្យមានការបញ្ជាក់យ៉ាងច្បាស់លាស់ដោយគ្រូពេទ្យជំនាញផ្នែកជំងឺបេះដូង ឬគ្រូពេទ្យព្យាបាល។<br>ចំពោះនិយមន័យខាងលើ រោគសញ្ញាខាងក្រោមមិនត្រូវបានរាប់បញ្ចូលឡើយ៖<br>- ការកើតមានអាការៈជំងឺសរសៃឈាមបេះដូងស្រួចស្រាល់មួយដែលរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹម ការឈឺទ្រូងមិនស្ថិតស្ថេរ។<br>- ការកើនឡើងនូវរូបធាតុជីវៈបេះដូងដែលបណ្ដាលមកពីការវះកាត់ព្យាបាលសរសៃឈាមបេះដូងដោយប្រើឧបករណ៍តាមសរសៃឈាម។ |
| **៣. ការវះកាត់សរសៃឈាមបេះដូងដែលឆ្លងកាត់កន្លែងដែលស្ទះ** | សំដៅដល់ការទទួលយកការវះកាត់ជាក់ស្ដែង ដោយមានការវះបើកដើមទ្រូងដើម្បីកែតម្រូវ និងព្យាបាលជំងឺសរសៃឈាមអាទែរក្នុងបេះដូង (កូរូណារី) ដោយការកាត់ផ្សាំសរសៃឈាមបេះដូងឆ្លងកាត់កន្លែងដែលស្ទះ។ |

| | |
|---|---|
| | ចំពោះនិយមន័យខាងលើ វិធីសាស្ត្រព្យាបាលខាងក្រោមមិនត្រូវបានរាប់បញ្ចូលឡើយ÷<br>(១) ការវះកាត់ព្យាបាលសរសៃឈាមបេះដូងដោយប្រើឧបករណ៍តាមសរសៃឈាម<br>(២) ពិនិត្យផ្ទៃខាងក្នុងសរសៃឈាម ឬការចោះដាក់បំពង់តូចក្នុងសរសៃឈាមដទៃទៀត<br>(៣) ការវះកាត់ព្យាបាលសរសៃឈាមបេះដូងតាមបច្ចេកទេសចោះឆ្អឹង (ការវះកាត់តាមដើមទ្រូងដោយមានមុខកាត់តូចហើយគ្មានការបំបែកឆ្អឹងទ្រូងឡើយ)<br>(៤) ការវះកាត់ដោយប្រើកាំរស្មី។ |
| **៤. ជំងឺដាច់/ស្ទះសរសៃឈាមខួរក្បាល (ស្ត្រូក)** - ដែលបណ្តាលឲ្យមានឱនភាពប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងរោគសញ្ញាគ្លីនិកជាប់លាប់ | ការស្លាប់ជាលិកាខួរក្បាលដោយសារការខ្វះឈាមទៅចិញ្ចឹម មានការហូរឈាមក្នុងលលាដ៍ក្បាល ឬមានស្ទះសរសៃឈាមបណ្តាលពីដុំកំណកឈាមដែលមានប្រភពពីខាងក្រៅលលាដ៍ក្បាលដែលបណ្តាលឲ្យមានឱនភាពប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងរោគសញ្ញាជាប់លាប់។ ការធ្វើរោគវិនិច្ឆ័យត្រូវពឹងផ្អែកលើលទ្ធផលមិនប្រក្រតីនៃការធ្វើស៊ីធីស្កែន ឬ ការថតអ៊ីមអរអាយ និងត្រូវបានបញ្ជាក់ពីគ្រូពេទ្យជំនាញខាងផ្នែកប្រព័ន្ធប្រសាទដែលបានចុះបញ្ជី។ រយៈពេលវាយតម្លៃអប្បបរមាចំនួន ៣) បី (ខែត្រូវយកមកអនុវត្ត។<br>ចំពោះនិយមន័យខាងលើ ជំងឺខាងក្រោមមិនត្រូវបានរាប់បញ្ចូលឡើយ÷<br>(១) រោគសញ្ញានៃការស្ទះសរសៃឈាមខួរក្បាលប្រភេទធីអាយអេ<br>(២) អាការៈរោគខួរក្បាលដោយសាររោគប្រកាំង<br>(៣) ការប៉ះទង្គិចដល់ជាលិកាខួរក្បាល ឬសរសៃឈាម<br>(៤) ជំងឺសរសៃឈាមដែលប៉ះពាល់ដល់ភ្នែក ឬសរសៃបាតភ្នែក ឬមុខងារទប់លំនឹងរាងកាយ។ |
| **៥. ការខ្សោយថ្លើមដំណាក់កាលចុងក្រោយ** | ការខ្សោយថ្លើមដំណាក់កាលចុងក្រោយមានអាការៈទាំងអស់ដូចខាងក្រោម÷<br>(១) ជំងឺខាន់លឿងជាអចិន្ត្រៃយ៍<br>(២) ទាចទឹក (ទឹកច្រើនលើសកម្រិតនៅក្នុងស្រោមពោះ) និង<br>(៣) ការចុះខ្សោយមុខងារខួរក្បាលដោយសារជំងឺថ្លើមធ្ងន់ធ្ងរ។ |

| | |
|---|---|
| | ការខូចថ្លើមដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬថ្នាំញៀនហួសកម្រិតមិនត្រូវបានរាប់បញ្ចូលនោះឡើយ។ |
| **៦. ជំងឺស្ទួតដំណាក់កាលចុងក្រោយ** | ជំងឺស្ទួតដំណាក់កាលចុងក្រោយបង្កឱ្យមានការខូចខាតប្រព័ន្ធដង្ហើមរ៉ាំរ៉ៃ។ លក្ខណៈវិនិច្ឆ័យទាំងអស់ខាងក្រោមត្រូវតែបំពេញ÷<br>(១) តម្រូវការជំនួយអុកស៊ីសែនជាទៀងទាត់ និងជាអចិន្ត្រៃយ៍<br>(២) ការចុះខ្សោយជាអចិន្ត្រៃយ៍នៃដំណើរការមុខងារសួតដែលការវាស់កម្រិតដង្ហើមចេញមក មានចំនួនតិចជាង ១ លីត្រខ្យល់ក្នុងរយៈពេលមួយវិនាទីដំបូងជាទៀងទាត់<br>(៣) ការដកដង្ហើមខ្លីៗ (ហត់) នៅពេលសម្រាក និង<br>(៤) ការធ្វើវិភាគមូលដ្ឋានឧស្ម័នក្នុងសរសៃឈាមអាទែរជាមួយនឹងសម្ពាធអុកស៊ីសែន ដែលមានកម្រិតត្រឹម 55 mmHg ឬតិចជាងនេះ។ |
| **៧. ការវះកាត់ផ្លាស់ប្តូរប្រឹសបេះដូងដោយបើកទ្រូង** | ប្រតិបត្តិការជាក់ស្តែងនៃការវះកាត់បើកទ្រូង ដើម្បីផ្លាស់ប្តូរ ឬជួសជុលប្រឹសបេះដូងដែលបណ្តាលមកពីការខូច ឬមិនប្រក្រតីពីកំណើត។ ការវះកាត់ជួសជុលតាមបច្ចេកទេសពិនិត្យផ្ទៃខាងក្នុងសរសៃឈាម ការវះកាត់ដោយបច្ចេកទេស ចោះឆ្លុះ ឬបច្ចេកទេសប្រហាក់ប្រហែលមិនត្រូវបានរាប់បញ្ចូលនោះទេ។ |
| **៨. ការវះកាត់ផ្លាស់ប្តូរសរីរាង្គសំខាន់ៗ** | ការវះកាត់ផ្លាស់ប្តូរសរីរាង្គមួយក្នុងចំណោមសរីរាង្គដូចខាងក្រោម÷<br>- បេះដូង<br>- សួត<br>- ថ្លើម<br>- តម្រងនោម<br>- លំពែង<br>ដែលបណ្តាលមកពីការខូចសរីរាង្គដែលមិនអាចជាសះស្បើយត្រឡប់វិញបាននៃសរីរាង្គដែលពាក់ព័ន្ធ។<br>ការវះកាត់ផ្លាស់ប្តូរកោសិកាដើម (ស្ទឹមសែល) ការវះកាត់ផ្លាស់ប្តូរកោសិកាតូចៗ (អាយស្លែតសែល) និងវះកាត់ផ្លាស់ប្តូរផ្នែកខ្លះនៃសរីរាង្គមួយមិនត្រូវបានរាប់បញ្ចូលឡើយ។ |

| | |
|---|---|
| **៩. ការខូចតម្រងនោម** | ការខ្សោយតម្រងនោមដំណាក់កាលចុងក្រោយគឺជាការខ្សោយតម្រងនោមទាំងពីររ៉ាំរ៉ៃដែលមិនអាចជាសះស្បើយវិញបាន ដែលតម្រូវឱ្យទទួលការព្យាបាលដោយលាងឈាមជាទៀងទាត់ ឬត្រូវវះកាត់ផ្លាស់ប្តូរតម្រងនោម។ |
| **១០. ការរលាកកម្រិតទី៣** | "ការរលាកកម្រិតទី៣" សំដៅទៅលើការរលាកគ្រប់ស្រទាប់ស្បែកទាំងមូលដែលគ្របដណ្តប់លើផ្ទៃស្បែកយ៉ាងហោចណាស់ ២០% (២០ភាគរយ) នៃផ្ទៃទាំងមូលនៃរាងកាយដែលបណ្តាលមកពីគ្រោះថ្នាក់។ ការរលាកស្បែកគួរតែត្រូវបានកំណត់ថាត្រូវការការព្យាបាលនៅមន្ទីរពេទ្យដែលបានចុះបញ្ជីហើយទាមទារឱ្យមានការវះកាត់សម្អាត។ |
| **១១.ការសន្លប់បាត់ស្មារតីដែលបន្តរហូតដល់យ៉ាងតិច ៩៦ (កៅសិបប្រាំមួយ) ម៉ោង** | ស្ថានភាពសន្លប់ដូចដែលត្រូវបានធ្វើរោគវិនិច្ឆ័យដោយគ្រូពេទ្យជំនាញផ្នែកសរសៃប្រសាទ ឬគ្រូពេទ្យវះកាត់ប្រព័ន្ធប្រសាទ។ ការធ្វើរោគវិនិច្ឆ័យនៃបញ្ហានេះត្រូវបានកំណត់ឡើងដោយវិធីសាស្ត្រដូចខាងក្រោម÷<br>- ត្រូវការឧបករណ៍ជំនួយដើម្បីទ្រទ្រង់ជីវិត<br>- គ្មានការឆ្លើយតបចំពោះការរំញោចខាងក្រៅយ៉ាងហោចណាស់ ៩៦ (កៅសិបប្រាំមួយ) ម៉ោង<br>- ខួរក្បាលត្រូវបានខូចខាតជាអចិន្ត្រៃយ៍ហើយមិនអាចធ្វើសកម្មភាពរស់នៅប្រចាំថ្ងៃ យ៉ាងហោចណាស់មួយសកម្មភាព ក្នុងរយៈពេលយ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃសន្លប់បាត់ស្មារតី។<br>ការសន្លប់ដែលបណ្តាលមកពីវេជ្ជសាស្ត្រ ឬការសន្លប់ដែលបណ្តាលមកពីការផឹកស្រាឬការប្រើប្រាស់គ្រឿងញៀនត្រូវបានបដិសេធជាពិសេស។ |
| **១២. ជំងឺខ្វះឈាមក្រហមដោយការខូចខួរឆ្អឹង (អេផ្លាស្ទិច អេនីមៀ)** | ស្ថានភាពនៃការខូចខួរឆ្អឹងជាអចិន្ត្រៃយ៍ត្រូវបានធ្វើរោគវិនិច្ឆ័យដោយលទ្ធផលនៃការវិភាគខួរឆ្អឹងដែលបណ្តាលឱ្យមានកង្វះឈាមក្រហម គោលិកាសធ្លាក់ចុះ ប្លាកែតធ្លាក់ចុះ និងតម្រូវអោយព្យាបាលយ៉ាងហោចណាស់ ២ (ពីរ) យ៉ាងក្នុងចំណោមវិធីសាស្ត្រព្យាបាលដូចខាងក្រោមនេះ÷<br>- ការបញ្ចូលផលិតផលឈាមទៀងទាត់<br>- ប្រើសារធាតុរំញោចខួរឆ្អឹង<br>- ប្រើសារធាតុរាំងខ្ទប់មុខងារប្រព័ន្ធភាពស៊ាំ<br>- ការវះកាត់ផ្សាំខួរឆ្អឹង។ |

| | |
|---|---|
| **១៣. ជំងឺប៉ាគីនសុន** | ការធ្វើរោគវិនិច្ឆ័យពិតប្រាកដនៃជំងឺប៉ាគីនសុន ដែលកើតឡើងឯកឯង ដោយគ្រូពេទ្យឯកទេសប្រព័ន្ធប្រសាទ ការធ្វើរោគវិនិច្ឆ័យនេះត្រូវបានកំណត់ដូចខាងក្រោម÷<br>- ជំងឺដែលមិនអាចគ្រប់គ្រងបានដោយឱសថ<br>- សញ្ញានៃការវិវត្តធ្ងន់ធ្ងរជាបន្តបន្ទាប់ និង<br>- អ្នកត្រូវបានធានារ៉ាប់រងអសមត្ថភាពក្នុងការធ្វើសកម្មភាពយ៉ាងតិច ៣ (បី) ក្នុងចំណោម ៦ (ប្រាំមួយ) នៃ “សកម្មភាពរស់នៅប្រចាំថ្ងៃ” ដោយគ្មានជំនួយពីអ្នកដទៃ ដែលបន្តក្នុងរយៈពេលមិនក្រោម ៦ (ប្រាំមួយ) ខែ។<br>រោគសញ្ញាដូចជំងឺប៉ាគីនសុន ដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំ ឬសារធាតុពុល មិនត្រូវបានរាប់បញ្ចូលនោះឡើយ។ |
| **១៤. ជំងឺវង្វេងវង្វាន់ (បាត់ការចងចាំ)** | ការចុះខ្សោយ ឬបាត់បង់សមត្ថភាពបញ្ញាជាបន្តបន្ទាប់ដែលត្រូវបានបញ្ជាក់ដោយការវាយតម្លៃនៃសញ្ញាគ្លីនិក និងការធ្វើតេស្តរូបភាពវេជ្ជសាស្ត្រ ដែលកើតឡើងពីជំងឺវង្វេងស្មារតី (អាល់ហ្សៃមើរ) ឬជំងឺសរីរាង្គដែលមិនអាចវិលត្រឡប់វិញបាន បណ្តាលឲ្យមានការថយចុះគួរឲ្យកត់សម្គាល់នូវមុខងារផ្លូវចិត្តនិងទំនាក់ទំនងសង្គមដែលតម្រូវឲ្យមានការថែទាំនិងការត្រួតពិនិត្យជាបន្តបន្ទាប់ចំពោះអ្នកត្រូវបានធានារ៉ាប់រង។ ការធ្វើរោគវិនិច្ឆ័យនេះត្រូវធ្វើឡើងដោយគ្រូពេទ្យឯកទេសផ្នែកប្រព័ន្ធប្រសាទនិងវេជ្ជបណ្ឌិតដែលមានការចាត់តាំងដោយក្រុមហ៊ុន។<br>ករណីខាងក្រោមនេះមិនត្រូវបានរាប់បញ្ចូលឡើយ÷<br>- ជំងឺដែលមិនបណ្តាលមកពីសរីរាង្គដូចជាជំងឺសរសៃប្រសាទ និងជំងឺផ្លូវចិត្ត និង<br>- ជំងឺប្រព័ន្ធប្រសាទដែលទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀន ឬអាល់កុល ឬជំងឺសរីរាង្គខួរក្បាលដែលខុសប្រក្រតីផ្សេងទៀត។ |